CEDAC

# កសិករ និង ធម្មជាតិ

# Farmer and Nature

[illegible] អភិវឌ្ឍន៍កសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា

លេខ ២ [illegible] | Nº 2, July 2004

# ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ (ប.វ.ស)



បណ្ឌិត យ៉ង សាំងកុមារ

ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ

Ecological System of Rice Intensification

និពន្ធដោយ : យ៉ង សាំងកុមារ

Yang Saing Koma

បោះពុម្ពលើកទី ១ នៅឆ្នាំ ២០០១ ចំនួន ១០០០០ ច្បាប់

បោះពុម្ពលើកទី ២ នៅឆ្នាំ ២០០៤ ចំនួន ២០០០០ ច្បាប់

បោះពុម្ពដោយ : រោងពុម្ពឥន្ទ្រីយ៍មាស

© សេដាក / CEDAC 2004

# ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ

# Ecological System of Rice Intensification

**បណ្ឌិត  យ៉ង  សាំងកុមារ**

**មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា**

**Centre d'Etude et de Développement Agricole Cambodgien (CEDAC)**

**ឆ្នាំ ២០០៤**

# មាតិកាអត្ថបទ

ទំព័រ

សេចក្តីថ្លែងអំណរគុណ

អារម្ភកថា

១. ប្រវត្តិរបស់ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ (ប.វ.ស) ........ ១

២. គុណសម្បត្តិរបស់ ប.វ.ស ........ ១

៣. គោលការណ៍ និងបច្ចេកទេសរបស់ ប.វ.ស ........ ២

៤. ការសរុបនូវគំនិតសំខាន់ៗ និងសំណូមពរបន្ថែម ........ ១២

រូបភាពទី ១: ស្រូវ ១ ដើម បែកគុម្ពច្រើន មានកួរច្រើន ........ ១

រូបភាពទី ២: តាមលក្ខណៈធម្មជាតិ ស្រូវ ១ ដើមអាចបែកគុម្ពបាន ៥០-៦០ ដើម ឬជួនកាលដល់ ១០០ ដើម ........ ២

រូបភាពទី ៣: ស្រែដែលធំមានផ្ទៃពុំរាបស្មើ និងការចែកកូនស្រែតូចៗ ហើយមានផ្ទៃរាបស្មើ ........ ៣

រូបភាពទី ៤: របៀបត្រាំគ្រាប់ពូជស្រូវក្នុងទឹកដើម្បីជ្រើសរើសយកគ្រាប់ពេញល្អ ........ ៣

រូបភាពទី ៥: របៀបស្រង់យកគ្រាប់អណ្តែតចេញ ........ ៤

រូបភាពទី ៦: ការរើសយកតែគ្រាប់ពេញសំរាប់សាប ឬព្រោះ ........ ៤

រូបភាពទី ៧: របៀបធ្វើថ្នាលសំណាបដូចរងស្លែ ........ ៤

រូបភាពទី ៨: របៀបរោយជីកំប៉ុស្តលើថ្នាលសំណាបមុនសាប ........ ៤

រូបភាពទី ៩: សំណាបដែលមានអាយុខ្លី និងមានដើមថ្លោសល្អ ........ ៥

រូបភាពទី ១០: ការស្ទូងសំណាប ១ ដើម ........ ៥

រូបភាពទី ១១: ការស្ទូងរាក់ ហើយមិនបត់ឫសដូចផ្លែសន្ទូច ........ ៥

រូបភាពទី ១២: របៀបស្ទូងជាជួរ (៧ ជួរ ដោយប្រើខ្សែចំនួន ២) ........ ៩

រូបភាពទី ១៣: ការស្ទូងជាជួរ និងឱ្យមានចំងាយស្មើៗគ្នា ........ ៩

រូបភាពទី ១៤: ការកាប់បង្ហូរទឹកចេញពីស្រែខ្លះនៅពេលទឹកដក់ក្នុងស្រែច្រើនពេក ........ ១០

រូបភាពទី ១៥: ការប្រមូលកាកសំណល់ផ្សេងៗធ្វើជីកំប៉ុស្ត ........ ១០

រូបភាពទី ១៦: ការព្រោះជីធម្មជាតិបំប៉នក្រោយពេលស្ទូងរួច ........ ១០

រូបភាពទី ១៧: ការដាំដំណាំជីស្រស់នៅវាលស្រែ ........ ១១

រូបភាពទី ១៨: សត្វល្អិតដែលរស់នៅក្នុងដី ជួយឱ្យដីផុសល្អ និងបង្កើនជីជាតិដល់ដី ........ ១១

# សេចក្តីថ្លែងអំណរគុណ


កូនសៀវភៅនេះកើតមានឡើង ដោយឈរលើមូលដ្ឋាននៃបទពិសោធន៍របស់កសិករខ្មែររាប់ពាន់នាក់មកពីខេត្តជាច្រើន ជាពិសេសពីខេត្តកណ្តាល កំពង់ធំ ព្រៃវែង តាកែវ ស្វាយរៀង កំពង់ចាម កំពត និងកំពង់ស្ពឺ។ ខ្ញុំបាទសូមថ្លែងអំណរគុណ និងវាយតំលៃខ្ពស់ចំពោះកសិករជាច្រើន ដែលយើងខ្ញុំមិនអាចរាយឈ្មោះទាំងអស់បាននៅពេលនេះ ដែលបានឈានមុខក្នុងការពិសោធន៍ ឬអនុវត្តន៍ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ (ប.វ.ស) ក៏ដូចជាជួយផ្សព្វផ្សាយដល់អ្នកដទៃនៅតាមភូមិរបស់ខ្លួន។

ទន្ទឹមនឹងនេះ ខ្ញុំសូមថ្លែងអំណរគុណដល់បុគ្គលិកមជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (ឬអង្គការសេដាក) និងបុគ្គលិករបស់អង្គការ ឬស្ថាប័នផ្សេងៗ ដែលបានចូលរួមចំណែកក្នុងការជួយជំរុញប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិនៅកម្ពុជា។

ជួសមុខឱ្យកសិករខ្មែរ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាគម **ទេហ្វីសៃណា** ឬ **"អភិវឌ្ឍន៍ផ្លូវចិត្ត"** (Tefy Saina) ជាពិសេសលោក **ហង់រី ដឺឡាឡូណេ** (Henri de Lalaunié) ដែលបានរកឃើញនូវ ប.វ.ស នៅ ប្រទេសម៉ាដាហ្គាស្កា និងលោកសាស្ត្រាចារ្យ **នរម៉ែន អ៊ុបហុហ្វ** (Norman Uphoff សាកលវិទ្យាល័យខ័រណែល នៅសហរដ្ឋអាមេរិក) ដែលដើរតួសំខាន់ក្នុងការគាំទ្រដល់អង្គការសេដាកក្នុងការផ្សព្វផ្សាយ ប.វ.ស នៅប្រទេសកម្ពុជា។

អ្នកស្រី **ទាស និមល** បានជួយក្នុងការវាយអត្ថបទ និងរៀបចំលំអកូនសៀវភៅនេះ។ លោក **យឹម សុផាណ្ណា** អ្នកស្រី **ពាន សុខា** លោក **ប្រាក់ សេរីវឌ្ឍន៍** លោក **ឡាង សេងហ៊ង** លោក **ឌិ ធី** លោក **ស៊ឹម សាធឿន** លោក **អ៊ី ណារ៉ុន** លោក **លុយ ពិសិរិទ្ធិ** បានជួយអានកែលំអអត្ថបទ។ ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមចំណែកដ៏មានតំលៃនេះ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះអង្គការអុកស្វាមអង់គ្លេស (Oxfam GB) និងអុកស្វាមអាមេរិក (Oxfam America) ក៏ដូចជាអង្គការ ប៉ាដិក (Padek) និងអង្គការដទៃទៀត ដែលបានជួយឧបត្ថម្ភថវិកាក្នុងការបោះពុម្ពសៀវភៅនេះ។

# អារម្ភកថា

បន្ទាប់ពីធ្វើការសាកល្បងនូវប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ បានជោគជ័យនៅឆ្នាំ ២០០០ កន្លងមក អង្គការសេដាក បានបោះពុម្ពផ្សាយនូវសៀវភៅស្តីពី ប.វ.ស នៅឆ្នាំ ២០០១។ កូនសៀវភៅដែលបោះពុម្ពផ្សាយលើកទី ១ មានចំនួន ២៤ ទំព័រ ហើយត្រូវបោះពុម្ពចំនួន ១០០០០ ច្បាប់។

ដោយតំរូវការលើកូនសៀវភៅ ប.វ.ស មានការកើនឡើង យើងបានសំរេចចិត្តធ្វើការបោះពុម្ពជាលើកទី ២ ចំនួន ២០០០០ ច្បាប់។ ចំពោះការបោះពុម្ពជាលើកទី ២ នេះ យើងបានធ្វើការកែលំអនូវខ្លឹមសារអត្ថបទ និងរូបភាព ដែលឈរលើមូលដ្ឋាននៃបទពិសោធន៍កន្លងមក។ ជាពិសេសធ្វើយ៉ាងណាដើម្បីឱ្យបងប្អូនកសិករងាយយល់ ងាយចាប់បាននូវគំនិតសំខាន់ៗ ក្នុងការអនុវត្តន៍ ប.វ.ស។

គោលបំណងសំខាន់របស់កូនសៀវភៅនេះ គឺចង់បង្ហាញឱ្យឃើញថា យើងពិតជាមានជំរើសសាមញ្ញៗ យ៉ាងច្រើនសំរាប់អនុវត្តក្នុងការបង្កើនផលស្រូវ ដោយមិនចាំបាច់អាស្រ័យទៅនឹងអ្វីដែលយើងហៅថាពូជទំនើប ឬពូជថ្មី ជីគីមី ថ្នាំពុល។ល។ យើងខ្ញុំជឿជាក់ថា ជំហានដំបូងនៃការអភិវឌ្ឍន៍កសិកម្មនៅកម្ពុជាយើង ជាពិសេសការបង្កើននូវផលិតកម្មស្រូវ គឺយើងគួរចាប់ផ្តើមពីការប្រើប្រាស់នូវអ្វីដែលមានស្រាប់ តាមរយៈការកែលំអនូវរបៀបដែលយើងធ្វើអ្វីមួយ និងរបៀបដែលកសិករសហការ និងរៀនសូត្រពីគ្នាទៅវិញទៅមក។

តាមបទពិសោធន៍កន្លងមករបស់កសិកររាប់ម៉ឺននាក់នៅកម្ពុជាយើង ក៏ដូចជា កសិករជាច្រើននាក់នៅប្រទេសផ្សេងៗទៀត ការកែលំអនូវផលិតកម្មស្រូវតាមគោលការណ៍ ប.វ.ស ពិតជាអាចជួយឱ្យគ្រួសារកសិករអាចបង្កើនផលបានលើសពីធម្មតា ដោយប្រើប្រាស់តែអ្វីដែលកសិករមានស្រាប់។ ភាពជោគជ័យកន្លងមករបស់កសិកររាប់ម៉ឺននាក់ បានបង្ហាញឱ្យឃើញថា ប.វ.ស ពិតជាអាចចូលរួមចំណែកក្នុងការលើកតំកើងជីវភាពគ្រួសារកសិករ កាត់បន្ថយនូវការបំពុលដល់បរិស្ថាន និងចំណីអាហារ និងជួយអភិរក្សនូវពូជស្រូវប្រពៃណីរបស់ខ្មែរយើង។ តាមរយៈកូនសៀវភៅនេះ ខ្ញុំសូមអំពាវនាវឱ្យបងប្អូនកសិករ និងអ្នកពាក់ព័ន្ធផ្សេងៗ ចាប់ដៃគ្នាដើម្បីជំរុញប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ ដើម្បីអភិវឌ្ឍន៍សហគមន៍យើង ប្រទេសយើងឱ្យក្លាយជាកន្លែងរស់នៅមួយដែលទឹក ដី និងចំណីអាហារគ្មានជាតិពុល។

ភ្នំពេញថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០០៤

**បណ្ឌិត យ៉ង សាំងកុមារ**

អ្នកនិពន្ធ និងជានាយកអង្គការសេដាក

## ១. ប្រវត្តិរបស់ ប.វ.ស

ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ ដែលហៅកាត់ថា "ប.វ.ស" គឺជាការផ្តុំចូលគ្នានូវបច្ចេកទេស ឬការអនុវត្តន៍ល្អៗ ដើម្បីជួយឱ្យស្រូវលូតលាស់បានល្អ និងបានផលច្រើន តាមសក្តានុពលធម្មជាតិរបស់វា។

គោលការណ៍ និងបច្ចេកទេសរបស់ ប.វ.ស ត្រូវបានបង្កើតឡើងលើកដំបូងដោយលោក ហង់រី ដឺឡាឡូឡេ (ជនជាតិបារាំង) នៅប្រទេសម៉ាដាហ្គាស្កា (កោះមួយនៅទ្វីបអាហ្វ្រិក) នៅក្នុងអំឡុងទសវត្សរ៍ទី ៨០។ អង្គការសេដាក បានចាប់ផ្តើមជំរុញ ប.វ.ស នៅប្រទេសកម្ពុជាក្នុងឆ្នាំ ២០០០។ នៅឆ្នាំដំបូងមានកសិករចំនួន ២៨ នាក់ នៅខេត្តចំនួន ៤ ដែលបានធ្វើការសាកល្បង។ ក៏ប៉ុន្តែដោយសារ ប.វ.ស អាចឱ្យកសិករអាចទទួលបានផលខ្ពស់ ២-៣ ដងលើសធម្មតា ហើយចំណាយតិច ជាពិសេសលើពូជ និងជីគីមី ធ្វើឱ្យកសិករជាច្រើនមានការចាប់អារម្មណ៍អនុវត្តតាម។ មកដល់ឆ្នាំ ២០០៣ ចំនួននេះបានកើនឡើងដល់ប្រហែល ១០០០០ នាក់ ហើយនៅឆ្នាំ ២០០៤ ក៏ដូចជាឆ្នាំខាងមុខៗនេះ ចំនួននឹងកើនឡើងកាន់តែច្រើនថែមទៀត។

## ២. គុណសម្បត្តិរបស់ ប.វ.ស

តាមបទពិសោធន៍កន្លងមក កសិករដែលអនុវត្តតាម ប.វ.ស អាចបង្កើនទិន្នផលស្រូវរបស់ខ្លួនបាន ២ ទៅ ៣ ដងលើសធម្មតា ហើយមានកសិករខ្លះអាចទទួលបានផលពី ៦ ទៅ ១០ តោន ក្នុងមួយហិកតា។ ឧទាហរណ៍ ដូចជាកសិករឈ្មោះ **គល់ នី** នៅភូមិត្រពាំងខន ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ អាចទទួលផលបាន ១០,៨ តោន ក្នុងមួយហិកតា ឬកសិករ **នឹម សៀង** នៅភូមិប្រាសាទ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ គាត់អាចទទួលបានផល ៧,៧ តោន ក្នុងមួយហិកតា។ លើសពីនេះទៀត កសិករអាចទទួលផលចំណេញពីការកាត់បន្ថយការចំណាយលើពូជ ការចំណាយលើជីគីមី ថ្នាំពុល និងការជួលកំលាំងពលកម្មសំរាប់ស្ទូង និងដកសំណាបថែមទៀតផង។ ឧទាហរណ៍ តាមការសិក្សារបស់អង្គការសេដាក លើកសិករ ១២០ នាក់ ដែល



រូបភាពទី ១ : ស្រូវ ១ ដើម បែកគុម្ពច្រើន មានកួរច្រើន

អនុវត្ត ប.វ.ស តាំងពីឆ្នាំ ២០០១ ជាមធ្យមមួយគ្រួសារអាចបង្កើនប្រាក់ចំណូលពីការធ្វើស្រូវបានប្រមាណ ៤៥០០០០ រៀល គ្រាន់តែអនុវត្ត ប.វ.ស ប្រហែលតែ ៣៥% នៃផ្ទៃដីស្រែរបស់គេប៉ុណ្ណោះ។

## ៣. គោលការណ៍ និងបច្ចេកទេសរបស់ ប.វ.ស

តាមលក្ខណៈធម្មជាតិរបស់វា ស្រូវអាចបែកគុម្ពបានរហូតដល់ ៥០-៦០ ដើម ឬជួនកាល ១០០ ដើម (ឧទាហរណ៍ស្រូវមួរ)។ តាមបទពិសោធន៍របស់យើងកន្លងមក ស្រូវនៅពេលបែកគុម្ពបានច្រើន នាំឱ្យមានដើមច្រើន កួរច្រើន កួរវែង គ្រាប់ធំ និងគ្រាប់ច្រើន។ បើនិយាយឱ្យខ្លី ស្រូវនៅពេលបែកគុម្ពបានច្រើន ផលក៏ច្រើនដែរ។

ក៏ប៉ុន្តែគួរឱ្យស្ដាយដែរ ដោយកន្លងមក ទំលាប់ ឬការអនុវត្តន៍របស់កសិករខ្មែរ មិនបានជួយឱ្យស្រូវលូតលាស់បានពេញលេញល្អតាមលក្ខណៈធម្មជាតិ។ នេះដោយសារកសិករយើងច្រើនដកបោក ចង ស្ទូងសំណាបអាយុចាស់ពេក ស្ទូងច្រើនដើមពេកក្នុងមួយគុម្ព (ចាប់ក្រាស់ពេក) ស្ទូងកប់ឫសចូលជ្រៅពេក ស្ទូងកៀកគ្នាពេក និងទុកទឹកដក់ច្រើនពេកក្នុងស្រែ។ល។



**រូបភាពទី ២ : តាមលក្ខណៈធម្មជាតិ ស្រូវ ១ ដើមអាចបែកគុម្ពបាន ៥០-៦០ ដើម ឬជួនកាលដល់ ១០០ ដើម**

ដើម្បីអាចឱ្យកសិករទទួលបានផលច្រើន ហើយចំណាយតិច ជាពិសេសលើការប្រើជីគីមី និងពូជ យើងគួរធ្វើការផ្លាស់ប្ដូរ ឬកែលំអទំលាប់មួយចំនួនចេញ ហើយចាប់ផ្ដើមអនុវត្តតាម ប.វ.ស។

ចំណុចសំខាន់ៗ ដែលកសិករគួរធ្វើការផ្លាស់ប្ដូរ ឬកែលំអមានដូចខាងក្រោមនេះ :

- ការធ្វើដីស្រែឱ្យរាបស្មើជាកត្តាមួយចាំបាច់ ពីព្រោះវាធានាឱ្យមានការផ្គត់ផ្គង់ទឹក និងជីជាតិបានស្មើល្អនៅក្នុងស្រែនិមួយៗ។ ដើម្បីងាយស្រួលទទួលបាននូវស្រែដែលមានដីរាបស្មើល្អ មានកសិករខ្លះចែកស្រែជាអំពកតូចៗ ហើយគេព្យាយាមធ្វើការពង្រាបជារៀងរាល់ឆ្នាំ។



រូបភាពទី ៣ : ថ្នាលស្រែដែលធំមានផ្ទៃមិនរាបស្មើ និងការចែកកូនថ្នាលស្រែតូចៗ ហើយមានផ្ទៃរាបស្មើ

មានកសិករខ្លះភ័យខ្លាចបាត់បង់ដីនៅពេលគេចែកដីស្រែជាអំពកតូចៗ ក៏ប៉ុន្តែតាមបទពិសោធន៍កន្លងមក យើងមានការបាត់បង់ដីខ្លះៗ ដើម្បីធ្វើស្រែមែន ក៏ប៉ុន្តែផលស្រូវកើនជាងមុនពេលចែកស្រែ។ ទន្ទឹមនឹងនេះ គេក៏អាចកាត់ស្មៅពីភ្លឺស្រែដើម្បីចិញ្ចឹមគោថែមទៀតផង។ ឧទាហរណ៍ អ៊ុំ ម៉ី សោម ដែលជាកសិករនៅ ភូមិត្រពាំងរាំង ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល បានចែកស្រែរបស់គាត់ដែលមានទំហំ ៥០ អារជា ៦ កូនស្រែតូចៗ។ បន្ទាប់ពីចែកស្រែហើយ គាត់បានទទួលផលស្រូវច្រើនជាងមុនពេលចែកស្រែ ទោះបីគាត់ត្រូវបានបាត់បង់ដីខ្លះតាមរយៈការលើកភ្លឺក៏ដោយ។

- ជ្រើសរើសយកតែគ្រាប់ដែលពេញល្អសំរាប់យកទៅសាប តាមរយៈការត្រាំទឹក (យកល្អទឹកដែលត្រាំគួរជាទឹកមានជាតិអំបិល ដោយដាក់អំបិល ១ ក្ដាប់ដៃ សំរាប់ទឹក ១ ប៉ោត) ដើម្បីស្រង់យកគ្រាប់ដែលមិនពេញចេញ (គ្រាប់ដែលអណ្ដែត)។ តាមបទពិសោធន៍កន្លងមក មានកសិករខ្លះបានយកគ្រាប់ពូជទៅត្រាំទឹកដែលមានជាតិស្ដៅ (ដោយត្រាំសំបក ស្លឹក ឬ គ្រាប់ស្ដៅ) ដើម្បីឱ្យស្រូវលូតលាស់បានល្អ និងជួយការពារសំណាបមិនឱ្យមានការបំផ្លាញពីសត្វល្អិត។



រូបភាពទី ៤ : របៀបត្រាំគ្រាប់ពូជស្រូវក្នុងទឹកដើម្បីជ្រើសរើសយកគ្រាប់ពេញល្អ



រូបភាពទី ៥ : របៀបស្រង់យកគ្រាប់អណ្តែតចេញ



រូបភាពទី ៦ : ការរើសយកតែគ្រាប់ពេញសំរាប់សាប ព្រោះ

- ធានាឱ្យបានសំណាបថ្លោសទៅស្ទូង តាមរយៈការធ្វើថ្នាលសំណាបគោក (ដូចរងស្តែ) ការប្រើជីកំប៉ុស្ត (ប្រហែល ៣-៥ គីឡូក្រាម លើដី ១ ម៉ែត្រក្រឡា) លើថ្នាល និងការសាបស្តើង (ពូជប្រហែល ១ គីឡូក្រាម សាបលើដីប្រហែល ៤០ ម៉ែត្រក្រឡា) ។



រូបភាពទី ៧ : របៀបធ្វើថ្នាលសំណាបដូចរងស្តែ



រូបភាពទី ៨ : របៀបអោយជីកំប៉ុស្តលើថ្នាលសំណាបមុនសាប

- ដកយកតែសំណាបដែលថ្លោសទៅស្ទូង ពីព្រោះសំណាបថ្លោសវាអាចដុះលូតលាស់ បែកគុម្ពបានល្អ



**រូបភាពទី ៩ : សំណាបដែលមានអាយុខ្ចី និងមានដើមថ្លោសល្អ**

- ស្ទូងសំណាបដែលអាយុខ្ចីជាងធម្មតា ឧទាហរណ៍ បើយើងធ្លាប់ស្ទូងសំណាបអាយុ ១ ខែកន្លះ យើងបន្ថយមកនៅ ៣០ ថ្ងៃ ឬ ២០ ថ្ងៃ ឬយើងធ្លាប់ស្ទូងសំណាបអាយុ ១ ខែ យើងបន្ថយមកនៅ ២០ ថ្ងៃ ឬ ១៥ ថ្ងៃ ពីព្រោះសំណាបដែលអាយុខ្ចីវាអាចមានពេលច្រើនសំរាប់បែកគុម្ព។ តែតាមបទពិសោធន៍របស់កសិករដែលធ្វើស្រែវស្សាកន្លងមក សំណាបដែលមានអាយុចន្លោះពី ១០ ទៅ ១៥ ថ្ងៃ អាចផ្តល់ផលបានល្អបំផុត។
- ស្ទូងដោយចាប់ស្តើងជាងធម្មតា ដោយបន្ថយមកចាប់ត្រឹម១-២ដើម ឬយកល្អតែមួយដើម ពីព្រោះស្រូវ ១ ដើមៗ បើវាមិននៅចង្អៀតគ្នាពេកទេ ឬបើវានៅតែឯងវាអាចមានលទ្ធភាពបែកគុម្ពបានល្អ។



**រូបភាពទី ១០ : ការស្ទូងសំណាប ១ ដើម**

- នៅពេលស្ទូង កុំស្ទូងកប់ឫសចូលក្នុងដីជ្រៅពេក ពីព្រោះវានាំឱ្យឫសមានការលំបាកក្នុងការលូតលាស់ (ហប់ខ្យល់) ហើយស្រូវពិបាកបែកគុម្ពដោយសារគល់ដើម (កន្លែងបែកខ្នែង) កប់ចូលជ្រៅពេក។ ដូចនេះនៅពេលយើងស្ទូង គួរដូរមកស្ទូងគ្រាន់តែផ្តិតឱ្យជាប់ដីបន្តិចៗបានហើយ។



**រូបភាពទី ១១ : ការស្ទូងរាក់ ហើយមិនបត់ឫសជូចផ្លែសន្ទូច**



➢ របៀបដកសំណាបទៅស្ទូង



➢ ឫសច្រើន ◄



➢ របៀបស្ទូងជាជួរលើដីផុសគ្មានទឹក





➢ របៀបធ្វើស្មៅ និងបំផុសដី



➢ គុម្ពស្រូវធ្វើតាមរបៀបធម្មត



→ ដើមច្រើន



ទ្រុងដីកំប៉ុស្ត





➢ ឧបករណ៍ធ្វើស្មៅ និងបំផុសដី



ធៀបជាមួយតាមរបៀប ប.វ.ស











- ស្ទូងឱ្យរង្វើលជាងធម្មតាបន្តិច ហើយយកល្អឱ្យមានជាជួរ ឬបន្ទាត់ ពីព្រោះវាបង្កលក្ខណៈងាយស្រួលឱ្យស្រូវអាចមានលទ្ធភាពបែកគុម្ពបានល្អ អាចទទួលសារធាតុចិញ្ចឹមបានស្មើៗគ្នា និងងាយស្រួលក្នុងការធ្វើស្មៅផង។ ដើម្បីជាជំនួយក្នុងការស្ទូងឱ្យត្រង់ជួរ គេអាចប្រើខ្សែ។ ឧទាហរណ៍ បើគេប្រើខ្សែចំនួន ២ គេអាចស្ទូងបានចំនួនជា ៥ ជួរ ឬ ៧ ជួរ បើគេប្រើខ្សែ ៣ គេអាចស្ទូងបានចំនួន ៧ ឬ ១១ ជួរ បើគេប្រើខ្សែចំនួន ៤ គេអាចស្ទូងបានចំនួន ៩ ឬ ១៥ ជួរ។ ដើម្បីធ្វើដូចនេះបាន គួរតែគូស ឬគួចខ្សែចំណាំនៅចន្លោះសំរាប់ស្ទូង និងចេះប៉ាន់ស្មាននូវជួរសំរាប់ស្ទូងនៅចន្លោះខ្សែ (រូបភាពទី ១២)។




**រូបភាពទី ១២ : របៀបស្ទូងជាជួរ (៧ ជួរ ដោយប្រើខ្សែចំនួន ២)**

- យើងគួរធ្វើការដកស្មៅ និងបំផុសដីស្រែរបស់យើងតាមរយៈការប្រើឧបករណ៍ផ្សេងៗ ជាជំនួយ (ចបរនាស់ ប្រដាប់រុញដកស្មៅ) ឬដកនឹងដៃ ពីព្រោះការដកស្មៅវាបណ្តាលឱ្យមានខ្យល់ចេញចូលក្នុងដីបានល្អ ដែលជួយឱ្យឫសស្រូវលូតលាស់បានច្រើន។ ក្រៅពីនេះទៀត ការដកស្មៅជួយកំចាត់នូវការប្រណាំង-ប្រជែងរបស់ស្មៅជាមួយដំណាំស្រូវ។




**រូបភាពទី ១៣ : ការស្ទូងជាជួរ និងឱ្យមានទំងាយស្មើៗគ្នា**



រូបភាពទី ១៤ : ការកាប់បង្ហូរទឹកចេញពីស្រែខ្លះនៅពេលទឹកដក់ក្នុងស្រែច្រើនពេក

- ប្រសិនបើអាចធ្វើបាន យើងគួរកុំឱ្យមានទឹកដក់ច្រើនក្នុងស្រែពេក យកល្អមានទឹកដក់បន្តិចៗបានហើយនៅពេលស្ទូង និងពេលស្រូវកំពុងបែកគុម្ព។ ការមិនមានទឹកដក់ ឬមិនមានទឹកដក់-ច្រើនក្នុងស្រែ វាបង្កលក្ខណៈឱ្យខ្យល់ចេញចូលក្នុងដីបានល្អ ដែលអាចជួយឱ្យឫសលូតលាស់បានប្រសើរ ហើយស្រូវក៏មិនលូតបណ្តោយតាមទឹក តែរីកទទឹងដែលធ្វើឱ្យដើមវាថ្លោស និងរឹងមាំ។
- យើងគួរប្រើជីធម្មជាតិឱ្យបានច្រើន ជាពិសេសការធ្វើជីកំប៉ុស្តប្រហែលពី ២ ទៅ ៤ តោន ក្នុងមួយហិកតា (សូមអានបន្ថែមនៅទំព័រទី ១១) និងការដាំជីស្រស់បៃតងលើស្រែនៅពេលមុនស្ទូង ឬក្រោយពេលច្រូត។ ម្យ៉ាងទៀត នៅពេលស្ទូងហើយ យើងនាំគ្នាគ្របដីតាមរយៈការព្រោះស្លឹកឈើ ចំបើង ស្មៅងាប់ គល់ជញ្ជ្រាំង។ល។ លើដីស្រែ ដើម្បីជួយរក្សាសំណើមការពារកុំឱ្យស្មៅដុះ និងបង្កើតជីបន្ថែមសំរាប់ស្រូវ (តាមរយៈការរលួយបំបែកធាតុ)។ សារៈសំខាន់នៃជីធម្មជាតិ គឺនៅពេលយើងប្រើទៅ វាជួយបង្កើតឱ្យមានសត្វល្អិតជាច្រើននៅក្នុងដី (ឧទាហរណ៍ ជន្លេន។ល។) ដោយសារសត្វល្អិតនេះហើយដែលអាចធ្វើឱ្យដីយើងផុស និងមានជីជាតិល្អ។



រូបភាពទី ១៥ : ការប្រមូលកាកសំណល់ផ្សេងៗធ្វើជីកំប៉ុស្ត



រូបភាពទី ១៦ : ការព្រោះជីធម្មជាតិក្រោយពេលស្ទូងរួច



រូបភាពទី ១៧ : ការដាំដំណាំជីស្រស់លើវាលស្រែ




រូបភាពទី ១៨ : សត្វល្អិតដែលរស់នៅក្នុងដី ជួយឱ្យដីផុសល្អ និងបង្កើនជីជាតិដល់ដី

ក្រៅពីចំណុចខាងលើនេះ យើងខ្ញុំ សូមបញ្ជាក់បន្ថែមថា ការប្រើប្រាស់ពូជដែលមានគុណភាពល្អ (ពូជសុទ្ធ ហើយមានគ្រាប់ពេញល្អ) ក៏ជាកត្តាមួយសំខាន់ក្នុងការបង្កើនទិន្នផលស្រូវដែរ។ ដោយអនុវត្តតាម ប.វ.ស តំរូវការពូជមានកំរិតទាប (ប្រហែលពី ៨-១២ គីឡូក្រាម ក្នុងមួយហិកតា) ដូចនេះ គេអាចប្រើប្រាស់កូនស្រែដែលមានទំហំពី ៣ ទៅ ៥ អារ សំរាប់ផលិត និងបន្សុទ្ធពូជស្រូវដោយខ្លួនឯង។ នៅលើស្រែដែលផលិតពូជនេះ គេត្រូវអនុវត្តបច្ចេកទេសដូចស្រែ ប.វ.ស ដែរ ក៏ប៉ុន្តែគេត្រូវស្ទូងតែមួយដើម ប្រើប្រាស់ជីធម្មជាតិបំប៉នឱ្យបានគ្រប់គ្រាន់ ដកស្មៅឱ្យបានល្អ និងជាពិសេសត្រូវដកចេញនូវគុម្ពណាដែលមានលក្ខណៈខុសគេ ឬខុសពីអ្វីដែលយើងប្រាថ្នាចង់បាន ដោយទុកតែគុម្ពណាដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាខ្លាំង ឬដូចគ្នាខ្លាំង (ការលូតលាស់ កំពស់ដើម ទំហំ និងប្រវែងរបស់កួរ ។ល។)។ ស្រូវដែលសំរាប់ទុកពូជត្រូវហាលឱ្យស្ងួត ហើយរក្សាទុកដាក់ដោយឡែកឱ្យបានល្អ។ ដោយកសិករម្នាក់ៗប្រើពូជច្រើនមុខ គេសហការគ្នាក្នុងការបែងចែកការបន្សុទ្ធពូជ ឬក៏យើងអាចជ្រើសរើសក្រុមកសិករដែលធ្វើការផលិតពូជសំរាប់ដោះដូរទៅតាមសហគមន៍។

ក្នុងចំណោមគំនិតសំខាន់ៗ ដែលរៀបរាប់ខាងលើនេះ អ្វីដែលប្លែកសំរាប់បងប្អូនកសិករយើង គឺការស្ទូង ១ ដើម ការស្ទូងសំណាបអាយុខ្លី ហើយការមិនមានដក់ទឹកច្រើន ឬដក់ជាប់នៅក្នុងស្រែ។ ចំពោះបងប្អូនកសិករខ្លះ វាជាការលំបាកក្នុងការអនុវត្តន៍តាម ពីព្រោះវាប្លែកខុសពីធម្មតា។ ក៏ប៉ុន្តែ ប្រសិនបើលោកអ្នកចង់បានផលស្រូវល្អខុសពីធម្មតា យើងគួរតែចាប់ផ្តើមអនុវត្តតាមគោលការណ៍ និងបច្ចេកទេស ប.វ.ស ដូចកសិកររាប់ម៉ឺននាក់ទៀត ដែលធ្លាប់សាកល្បងបានជោគជ័យរួចមកហើយ។

## ៤. ការសរុបនូវគំនិតសំខាន់ៗ និងសំណូមពរបន្ថែម

តាមបទពិសោធន៍កន្លងមក យើងអាចសន្និដ្ឋានបានថា គោលការណ៍ និងបច្ចេកទេស ប.វ.ស ជាជំរើសមួយសមស្របសំរាប់កសិករខ្មែរក្នុងការបង្កើនទិន្នផលស្រូវ។ ជាពិសេសជាងនេះទៀត ការអនុវត្តន៍ ប.វ.ស គឺមិនចាំបាច់ត្រូវការទុន ឬធនធានអ្វីពិសេសបន្ថែម ក្រៅពីអ្វីដែលកសិករមានស្រាប់ (ដី ពូជ ទឹក ជីធម្មជាតិ)។ អ្វីដែលជាកត្តាសំខាន់សំរាប់ឱ្យកសិករយើងអាចអនុវត្ត ប.វ.ស បានជោគជ័យ គឺភាពក្លាហាន និងភាពច្នៃប្រឌិតក្នុងការសាកល្បងនូវអ្វីមួយថ្មី។

សរុបមក ចំណុចសំខាន់ៗបំផុតដែលបងប្អូនកសិករគួរធ្វើការផ្លាស់ប្តូរ ឬសាកល្បងកែលំអមានដូចជា :

- ☞ ជ្រើសរើសគ្រាប់ពេញល្អយកទៅសាប
- ☞ ជ្រើសរើសយកតែសំណាបដែលថ្លោសល្អ ឬមានសុខភាពល្អ
- ☞ បន្ថយអាយុសំណាបដែលត្រូវស្ទូង
- ☞ បន្ថយចំនួនដើមដែលត្រូវស្ទូងក្នុងមួយគុម្ព

- ☞ ពង្រីកចន្លោះគុម្ពដែលត្រូវស្ទូង
- ☞ ស្ទូងឱ្យមានជាជួរបន្ទាត់ល្អ
- ☞ បន្ថយជំរៅកប់ឫសពេលស្ទូង ( ស្ទូងថ្នម ហើយរាក់ជាងមុន)
- ☞ បន្ថយទឹកកុំឱ្យមានដក់ច្រើន ឬដក់ជាប់នៅក្នុងស្រែ
- ☞ បង្កើនការប្រើជីធម្មជាតិ

នៅពេលលោកអ្នកធ្វើការអនុវត្តន៍ សូមព្យាយាមផ្គុំចូលគ្នានូវចំណុចសំខាន់ៗទាំងនេះ។ កាលណាយើងអាចផ្គុំចូលគ្នាបានច្រើនចំណុច នោះផលក៏កើនកាន់តែច្រើនដែរ។ ផ្ទុយទៅវិញ បើយើងមិនបានផ្គុំចូលគ្នានូវចំណុចទាំងនេះ ជួនកាលអាចឱ្យយើងមិនអាចបានផលច្រើនដូចការរំពឹងទុកទេ។ ឧទាហរណ៍ បើលោកអ្នកស្ទូងសំណាបខ្ចីស្ទូង ១ ដើម តែស្រែមានទឹកដក់ច្រើនពេក ក៏ស្រូវរបស់យើងមិនអាចលូតលាស់បានល្អដែរ។ ម្យ៉ាងទៀត បើអាយុសំណាបយើងចាស់ យើងក៏នៅអនុវត្តតាម ប.វ.ស បានដែរ គឺយើងស្ទូង ១ ដើម ឬ ២ ដើម ស្ទូងជាជួរ ហើយស្ទូងរាងក្បៀកជាងការស្ទូងសំណាបខ្ចីបន្តិច។

ប្រសិនបើលោកអ្នកមានការលំបាកក្នុងការផ្លាស់ប្តូរទំលាប់ ឬមិនទាន់ហ៊ានប្រថុយក្នុងការផ្លាស់ប្តូរទំលាប់យ៉ាងអន់ណាស់យើងក៏គួរសាកល្បងបន្ថយចំនួនដើមដែលត្រូវស្ទូងក្នុងមួយគុម្ព ឱ្យមកនៅត្រឹមតែពី ១-៣ ដើម ដោយប្រើតែសំណាបថ្លោសៗសំរាប់ស្ទូង និងស្ទូងដោយរាក់ជាងធម្មតា ឬការប្តូរពីទំលាប់ស្ទូងមិនត្រង់ជួរ មកស្ទូងជាជួរ។ល។ ប្រសិនបើលោកអ្នកផ្លាស់ប្តូរតែ ២-៣ ចំណុចនេះ លោកអ្នកក៏អាចបានទទួលផលច្រើនជាងធម្មតា។ នៅពេលនោះ លោកអ្នកអាចចាប់ផ្តើមឈានទៅរកការផ្លាស់ប្តូរបន្ថែមទៀត ដោយធ្វើយ៉ាងណាឱ្យការធ្វើស្រែបានផលកាន់តែប្រសើរ ចំណេញកាន់តែខ្ពស់ ជីជាតិដីក៏នៅគង់វង្សបានល្អ ហើយការអាស្រ័យលើជីគីមី ថ្នាំពុល ត្រូវបានកាត់បន្ថយ ឬកាត់ផ្តាច់តែម្តង។

ប្រសិនបើបងប្អូនកសិករចង់បានការរីកចំរើនល្អ ក្នុងការធ្វើស្រែទាល់តែបងប្អូនចាប់ផ្តើមធ្វើការផ្លាស់ប្តូរនូវទំលាប់ ឬការអនុវត្តន៍កន្លងមក ហើយការផ្លាស់ប្តូរអាចជាការផ្លាស់ប្តូរទាំងស្រុង ឬការផ្លាស់ប្តូរបន្តិចម្តងៗ ឬធ្វើការសាកល្បងនៅលើផ្ទៃដីតូចសិនដើម្បីរៀនសូត្រ។

**"ដើម្បីឱ្យមានការរីកចំរើន ទាល់តែយើងផ្លាស់ប្តូរចាប់យកអ្វីមួយថ្មី ឬប្រសើរជាងមុន"**

# ឧបសម្ព័ន្ធ

## ជីកំប៉ុស្តគោក

### ក- ជីកំប៉ុស្ត និងសារៈសំខាន់របស់វា

ជីកំប៉ុស្ត គឺជាជីដែលផ្គុំឡើងដោយសារធាតុសរីរាង្គផ្សេងៗ ដែលគេទុកឱ្យបំបែកធាតុ (ពុក) ក្នុងរយៈ-ពេលកំណត់មួយសិន មុននឹងយកមកប្រើ។

គោលបំណងសំខាន់នៃការធ្វើជីកំប៉ុស្ត គឺផលិតនូវសារធាតុសំបូរទៅដោយសត្វល្អិតដែលផ្តល់ជីវិតដល់ដីសំបូរសារធាតុសំរាប់ចិញ្ចឹមជីវិតដំណាំ និងអាចជួយឱ្យដីមានសមត្ថភាពគ្រប់គ្រាន់សំរាប់ស្រូបយកទឹក និងសារធាតុចិញ្ចឹមបានច្រើន។

### ខ- របៀបធ្វើជីកំប៉ុស្ត

ធនធានសំរាប់ធ្វើជីកំប៉ុស្តមាន :

- ធាតុស្ងួត ឬធាតុដែលសំបូរកាបោន ដូចជា : ចំបើង ស្មៅស្ងួត ស្លឹកឈើ អាចម៍រណារ ...
- ធាតុសើម ឬពពួកសំបូរជាតិអាសូត ដូចជា : ស្លឹកឈើស្រស់ (ស្លឹកពពួកដំណាំកួរ ឬពពួកសណ្តែក) អាចម៍សត្វ កាកសំណល់ផ្ទះបាយ
- ដី អាចជាដីស្រទាប់លើ ឬដីដំបូក ឬ ជីកំប៉ុស្តចាស់

នៅពេលធ្វើជីកំប៉ុស្ត គេអាចលាយធាតុទាំង ៣ នេះបាន ២ របៀប :

១) រៀបវាជាស្រទាប់ៗ

២) លាយចូលគ្នាទាំងអស់តែម្តង

ជាទូទៅការរៀបស្រទាប់ មានលក្ខណៈប្រសើរជាងការលាយចូលគ្នាទាំងអស់។ ការរៀបជាស្រទាប់ៗ វាមិនទាមទារឱ្យយើងត្រឡប់ទេ (ការត្រឡប់មិនចាំបាច់ទេ) ហើយក៏វាមានភាពងាយស្រួលក្នុងការរក្សាតុល្យភាពរវាងធាតុស្ងួត ធាតុសើម និងដី

ចំពោះការរៀបជាស្រទាប់ៗ គេអនុវត្តដូចខាងក្រោមនេះ :

- ស្រទាប់ទី ១ : ធាតុស្ងួត(៣ ដង)
- ស្រទាប់ទី ២ : ធាតុសើម(២ ដង)
- ស្រទាប់ទី ៣ : ដី (១ ទៅកន្លះដង)

ការរៀបជាស្រទាប់របៀបនេះរហូតដល់ទ្រុងជី ឬរណ្តៅជីពេញ។

## បរិមាណសារធាតុសំខាន់ៗទាំង ៣ នៅពេលលាយចូលគ្នាធ្វើជាកំប៉ុស្ត



ដី ( ដីស្រទាប់លើ ឬដីបាតត្រពាំង ... )
លាយជាមួយផេះ និងកំប៉ុស្ត

ធាតុសើម ( ពពួកសំបូរអាសូត N )

សារធាតុស្ងួត ពពួកសំបូរកាបូន ( C )



ការគ្របទ្រុងដីកំប៉ុស្ត





ទ្រុងដីកំប៉ុស្តដែលធ្វើនៅក្រោមដើមឈើ

### ឥ- ចំណុចដែលត្រូវចងចាំនៅពេលធ្វើ និងប្រើជីកំប៉ុស្ត

ដើម្បីផលិតឱ្យបានជីកំប៉ុស្តដែលមានគុណភាពល្អ ត្រូវចងចាំនូវចំណុចមួយចំនួនដូចខាងក្រោម :

☞ ត្រូវប្រើសារធាតុសរីរាង្គ ឱ្យបានច្រើនប្រភេទសំរាប់ធ្វើជីកំប៉ុស្ត

☞ ត្រូវរក្សាឱ្យមានតុល្យភាពរវាងធាតុស្ងួតនិងធាតុសើម ជៀសវាងកុំឱ្យធាតុស្ងួតច្រើនពេក ឬសើមពេក

☞ គំនរជីកំប៉ុស្តត្រូវធានាឱ្យមានខ្យល់ចេញចូល ពីព្រោះវាបង្កឱ្យមានសត្វតូចៗ មានប្រយោជន៍ច្រើនដែលមានតួនាទីសំខាន់ជួយឱ្យដីមានជីជាតិល្អ និងដំណាំលូតលាស់បានល្អ។ ដើម្បីជួយឱ្យមានខ្យល់ចេញចូលបានល្អ គេត្រូវឧស្សាហ៍ត្រឡប់ជី។ ម្យ៉ាងវិញទៀត គេអាចដាក់បំពង់ឫស្សីដែលមានប្រហោងដោតនៅកណ្តាលគំនរ ជីដើម្បីនាំខ្យល់ចូល។ គេត្រូវជៀសវាងធ្វើជីក្នុងរណ្តៅដែលមានទឹកដក់ជាប់ ជាពិសេសនៅរដូវវស្សា។

☞ ចំពោះនៅរដូវរាំងស្ងួត ហើយធាតុផ្សំរបស់ជីសំបូរទៅដោយសារធាតុស្ងួត យើងគួរឧស្សាហ៍ស្រោចទឹកបន្ថែមលើជី។

☞ រណ្តៅ ឬគំនរជីកំប៉ុស្តត្រូវគ្របឱ្យបានល្អ ដើម្បីការពារកុំឱ្យសារធាតុអាសូតហើរចេញ។

☞ ជីកំប៉ុស្តដែលរួចរាល់ហើយសំរាប់ប្រើមានគុណភាពល្អ គឺមិនមានក្លិនស្អុយ (មានក្លិនល្អ) មិនក្តៅ រលួយចូលគ្នាអស់ (ដោយមិនអាចឱ្យយើងស្គាល់បានថាតើ ធាតុណាជាធាតុអ្វី)។ ប្រសិនបើវាមិនទាន់កាច់អស់ទេ នៅពេលយើងយកទៅប្រើ វានឹងបញ្ចេញកំដៅដែលប៉ះពាល់ដល់ឫសដំណាំ និងលូតលាស់របស់ដំណាំ។

☞ គេអាចយកជីកំប៉ុស្តទៅត្រាំនឹងទឹក ហើយយកទឹកជីនេះស្រោចបំប៉នដល់សំណាបឱ្យលូតលាស់បានល្អ។

☞ ដើម្បីឱ្យសំណាបលូតលាស់បានល្អ ហើយងាយដកយកទៅស្ទូង គេយកជីកំប៉ុស្តទៅរោយលើថ្នាលសំណាប ហើយរាស់ចូលក្នុងដីបន្តិចៗ។ បន្ទាប់មក គេធ្វើការសាបលើថ្នាលយកតែម្តង។

**"ប្រើជីកំប៉ុស្តទើបដីវាផុស ប្រើជីគីមីខុសនាំឱ្យដីរឹង"**

## មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក/CEDAC)

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ជាអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ឯករាជ្យ មិនស្វែងរកកំរៃផលប្រយោជន៍បុគ្គល និងមិនពាក់ព័ន្ធគណបក្សនយោបាយ ។ "សេដាក" ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៧ ក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍន៍សង្គមកម្ពុជាមួយប្រកបដោយចីរភាព និងសមធម៌ ដែលប្រជាកសិករ និងអ្នកបរិភោគមានជីវិតរស់នៅប្រកបដោយភាពសប្បាយរីករាយ ។

សេដាក បានចាប់ដៃជាមួយកសិករ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីផ្តួចផ្តើមគំនិតអនុវត្ត និងគាំទ្រដល់គំរោង ឬសកម្មភាពដែលចូលរួមចំណែកដល់អធិបតេយ្យភាពស្បៀង និងការបង្កើនទូវគុណភាពនៃជីវិតរបស់ប្រជាកសិករ និងអ្នកបរិភោគ ដោយជាមួយគ្នានោះរក្សា និងបង្កើនទូវគុណភាពនៃធនធាន-ធម្មជាតិ និងការសហការគ្នាក្នុងសង្គម ។

☞ ចងក្រង និងបោះពុម្ពផ្សាយដោយ ***មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក/*** *CEDAC)*

☞ *ឧបត្ថម្ភថវិកាដោយអង្គការអុកស្វាមអង់គ្លេស (Oxfam GB)*

*អុកស្វាមអាមេរិក (Oxfam America) និងអង្គការប៉ាដិក (Padek)*

☞ *ពត៌មានផ្សេងៗ និង ការបែងចែកផ្សព្វផ្សាយ សូមទំនាក់ទំនង*

*ផ្ទះលេខ ៣៩ ផ្លូវលេខ ៥២៨ សង្កាត់បឹងកក់ ១ ខ័ណ្ឌទួលគោក*

*ប្រអប់សំបុត្រលេខ ១១១៨ រាជធានីភ្នំពេញ*

*ទូរស័ព្ទ: (០២៣) ៨៨០៩១៦ ទូរសារ: (០២៣) ៨៨៥១៤៦ E.mail : Cedac@camnet.com.kh*

# ប្រសិនបើលោកអ្នកចង់បានទិន្នផលស្រូវខ្ពស់ ហើយចំណាយតិច សូមសាកល្បងអនុវត្តន៍បច្ចេកទេសសំខាន់ៗ ទាំង ១២ របស់ ប.រ.ស

ប្រើជីធម្មជាតិ ជាពិសេស ជីកំប៉ុស្ត ដើម្បីឱ្យដីផុស បានល្អ

ធ្វើដីឱ្យរាបស្មើ និងមាន ប្រព័ន្ធសំរាប់បញ្ចេញទឹក

ដកស្មៅបំផុសដីឱ្យបាន ២ ទៅ ៤ ដងដើម្បីឱ្យខ្យល់ ចេញចូល

ជៀសវាងកុំឱ្យមានទឹក ដក់ច្រើនក្នុងស្រែពេល ស្រូវកំពុងលូតលាស់

ប្រើពូជសុទ្ធល្អ និងរើសតែ គ្រាប់ពេញល្អសំរាប់សាប



ស្ទូងឱ្យរង្វើលពីគ្នា ដោយ ចន្លោះឆាកពី ២,៥ តឹក ទៅ ៤ តឹក

ធ្វើថ្នាលសំណាបគោក ហើយសាបស្តើង ដើម្បីឱ្យសំណាបថ្លោស

ស្ទូងជាជួរដោយចម្ងាយពី គុម្ពមួយ ទៅគុម្ពមួយស្មើគ្នា

ដកតែសំណាបថ្លោសទៅស្ទូង ដោយដកថ្នមៗ ហើយដក ភ្លាមស្ទូងភ្លាម

ស្ទូងសំណាបអាយុខ្លី យកល្អអាយុតិចជាង ១៥ ថ្ងៃ

ស្ទូងចាប់ស្តើងយកល្អស្ទូង តែ ១ ដើម ក្នុង ១ គុម្ព

ស្ទូងថ្នមៗ រាក់ៗ និង កុំបត់ឫសដូចផ្លែសន្ទូច